**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំណត់ហេតុ**

**ប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍**

**ថ្ងៃ ច័ន្ទ ទី ៧ ខែ មេសា ឆ្នាំ ២០១៤ នៅសាលប្រជុំ អ.ជ.ប.ជ.អ**

នៅវេលាម៉ោង ៩:០០ ព្រឹក ថ្ងៃច័ន្ទទី៧ ខែមេសា ឆ្នាំ២០១៤ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានរៀបចំកិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍ របស់ខ្លួនក្រោមការដឹកនាំកិច្ចប្រជុំដោយ ឯកឧត្តម វេជ្ជបណ្ឌិត តែង គន្ធី អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការចូលរួមពីអគ្គលេខាធិការរង ប្រធាន និងអនុប្រធាន នាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាន។

**១. សមាសភាពចូលរួម៖**

សមាសភាពចូលរួមក្នុងកិច្ចប្រជុំថ្ងៃនេះ មានអគ្គលេខាធិការរងប្រធាននាយកដ្ឋានអនុប្រធាននាយកដ្ឋាន សរុបទាំងអស់ ចំនួន ១៣រូប (មានភ្ជាប់ជូនបញ្ជីវត្តមានអ្នកចូលរួមនៅក្នុងឧបសម្ព័ន្ធ)។

## ២. អវត្តមានៈ

១-លោកវេជ្ជ រស់ សីលវ៉ាត់ អគ្គលេខាធិការរង អ.ជ.ប.ជ.អ (បេសកកម្ម)

២-លោកស្រីវេជ្ជ ងិន លីណា ប្រធាននា. PMER (ប្រជុំGARPR)

៣-លោកស្រីវេជ្ជ. ស៊ូ សុភី អនុប្រធាននា. PMER (សុំច្បាប់)

៤-លោកវេជ្ជ. យង់ សុវណ្ណនា ប្រធាននា. បង្ការថៃទាំ និងគាំទ្រ (សុំច្បាប់)

៥-លោកវេជ្ជ. អ៊ុក ម៉ារឌី អនុប្រធាននា. បង្ការ ថៃទាំ និងគាំទ្រ (អវត្តមាន)

៦-លោក ហាង វិបុល អនុប្រធាននា. រដ្ឋបាល និងហិរញ្ញវត្ថុ (អវត្តមាន)

៧-លោក រ៉ឹង យ៉ាណាត អនុប្រធាននា.ទាក់ទងនិងចលនាប្រភពធនធាន (បេសកកម្ម)

## ៣. ប្រធានបទនៃកិច្ចប្រជុំ ៖

៣.១.ពិនិត្យ និងតាមដានសកម្មភាពការងារតាមរយៈកំណត់ហេតុកិច្ចប្រជុំលើកមុន

៣.២.វេទិកាពិភាក្សាលើបញ្ហាសំណូមពរ និងអនុសាសន៍

៣.៣.ប្រធានបទផ្សេងៗ

## ៤. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជ. តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានមតិស្វាគមន៍ចំពោះ ឯកឧត្តម លោក លោកស្រី អគ្គលេខាធិការរង ប្រធាន និងអនុប្រធាន នាយកដ្ឋានទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំនាព្រឹកនេះ។ឯកឧត្តមប្រធានអង្គប្រជុំក៏បានលើក ឡើងថ្លែងអំណរគុណចំពោះការចូលរួមរបស់ ឯកឧត្តម លោក លោកស្រី ទាំងអស់ ដែលចូលរួម ក្នុងកិច្ចប្រជុំតាមកាលកំណត់សំរាប់ខែនេះ។ ឯកឧត្តមមានប្រសាសន៍ថានៅសប្តាហ៍នេះ លោកជូន

ជាអនុសាសន៍សំរាប់នាយកដ្ឋាននីមួយៗ ជាពិសេសការងារពាក់ព័ន្ធជាមួយនាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ ដូចខាងក្រោមនេះ៖

**ការងាររដ្ឋបាល៖**

- ស្នើនាយកដ្ឋានរដ្ឋបាលកែសំរួលលើការសុំច្បាប់សំរាប់មន្ត្រី និងរៀបចំកិច្ចប្រជុំអញ្ជើញមន្ត្រី ទាំងអស់ចូលរួមដោយពន្យល់គាត់ពីបែបបទនៃការសុំច្បាប់ឈប់សំរាក។
- ស្នើរដ្ឋបាលផ្ទៀងផ្ទាត់បេសកកម្មជាមួយនឹងបញ្ជីវត្តមានរបស់មន្ត្រីដើម្បីចៀសវាងការចុះហត្ថលេខាត្រួតគ្នាដែលធ្វើអោយប៉ះពាល់ដល់ការធ្វើសវនកម្ម។
- ស្នើរដ្ឋបាល និងប្រធាននាយកដ្ឋានទាំងអស់ជូនដំណឹងដល់អនុប្រធាននាយកដ្ឋានពីការចូលរួមក្នុងកិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ជាចាំបាច់ប្រសិនមានការចាំបាច់ត្រូវសុំច្បាប់។

**ការងារបច្ចេកទេស៖**

- ស្នើរដ្ឋបាលពិនិត្យមើល LoA អោយបានត្រឹមត្រូវមុនបញ្ជូនទៅ SSRs ចុះហត្ថលេខា។
- រាល់កិច្ចសន្យាទាំងអស់ត្រូវមានចុះហត្ថលេខាបំព្រួញ។
- ស្នើលោកប្រធាននាយកដ្ឋានទទួលខុសត្រូវលើការងាររបាយការណ៍ហិរញ្ញវត្ថុដែលត្រូវផ្ញើទៅPR
- ស្នើរដ្ឋបាលបញ្ជូនបញ្ជីវត្តមានទៅគ្រប់នាយកដ្ឋានចុះហត្ថលេខា និងត្រូវប្រគល់មកនាយកដ្ឋានវិញនៅរាល់ថ្ងៃសុក្រដោយប្រធាននាយកដ្ឋានជាអ្នកទទួលខុសត្រូវការងារនេះ។
- ស្នើប្រធាននាយកដ្ឋានពិនិត្យមើលការងារតំឡើងកាំប្រាក់មន្ត្រីរាជការក្នុងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដល់ណាហើយ?លោកប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុបានជំរាបថាយោងតាមការសំរេចឯកឧត្តមទេសរដ្ឋមន្ត្រីបានអនុញ្ញាតអោយរៀបចំសមាសភាពគណៈកម្មការដើម្បីធ្វើការវាយតម្លៃថាមន្ត្រីណាដែលត្រូវឡើងកាំប្រាក់និងឋានៈ។ខាងរដ្ឋបាលបានរៀបចំរួចហើយ ៗ

ដោយមានឯកឧត្តមសាស្ត្រាចារ្យលីប៉ូរជាប្រធាន។ ប៉ុន្តែមកទល់ពេលនេះ ពុំទាន់បានទទួលការអនុញ្ញាតពីឯកឧត្តមសាស្ត្រាចារ្យរៀបចំកិច្ចប្រជុំនេះនៅឡើយ។

**៥. សំណូមពរ និងប្រធានបទផ្សេងៗ:**

**ឯកឧត្តមប្រធានអង្គប្រជុំ** បានមានប្រសាសន៍លើកឡើងថា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងប្រារព្ធពិធីសូត្រមន្តចូលឆ្នាំប្រពៃណីខ្មែរនៅថ្ងៃទី១០ខែមេសាឆ្នាំ២០១៤ដែលមានកម្មវិធីដូចខាងក្រោមៈ

- ប្រគំភ្លេងពិណពាទ្យ
- ពិធីសូត្រមន្តអបអរបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរនិងពិធីជូនពរឯកឧត្តមទេសរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ពិធីរាំរបាំត្រុដិ
- ពិសាអាហារសាមគ្គីនិងរាំកំសាន្ត

**លោកវេជ្ជ លី ចាន់រ៉ាវុធ** បានលើកឡើងថាលោកទើបតែត្រឡប់ពីបន្តការសិក្សានៅប្រទេសអូស្ត្រាលីចូលបំរើការងារវិញនៅឆ្នាំ២០១៤ តើឈ្មោះលោកត្រូវបានទទួលថវិកា POC ដែរឬទេ? លោកប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុបានបកស្រាយថាសំរាប់ថវិកាPOCជំហានទី២នេះ លោកស្រី ប្រធាននាយកដ្ឋានបានបញ្ចូលឈ្មោះលោក លី ចាន់រ៉ាវុធ ទៅក្នុងបញ្ជី និងបានបញ្ជូនទៅ PR រួចហើយតែត្រូវរង់ចាំគេអនុម័តសិន។

**ឯកឧត្តមវេជ្ជ ស៊ឹម គឹមសាន** បានលើកឡើងថា នាយកដ្ឋានលោកបានរៀបចំផែនការសំរាប់ចុះបេសកកម្ម ដោយបានអនុម័តពីឯកឧត្តមអគ្គលេខាធិការរួចហើយតែខាងរដ្ឋបាល ពុំបានរៀបចំបេសកកម្មអោយទេ។ ឯកឧត្តមអគ្គលេខាធិការ បានបំភ្លឺថាលោកបានអនុម័តជារួមតែជាក់ស្តែង

ឯកឧត្តមស្នើអោយមានដាក់សំណើចុះបេសកកម្មដោយមានបញ្ជាក់ឈ្មោះ ចំនួនថ្ងៃ និងទីកន្លែង ត្រូវចុះជូនលោកចុះហត្ថលេខា។

លោក **ឈឹម ឃិនដារ៉េត** បានលើកឡើងថាការរៀបចំគំរោងផែនការថវិកាជាតិ សំរាប់ឆ្នាំ២០១៥ ត្រូវផុតកំណត់នៅខែឧសភាឆ្នាំ២០១៥ ដោយមិនបានបញ្ចូលជាមួយក្រសួងសុខាភិបាលទៀតទេ។ ឯកឧត្តមអគ្គលេខាធិការបានស្នើលោកប្រធាននាយកដ្ឋានរដ្ឋបាលរៀបចំលិខិតអញ្ជើញសំរាប់រៀបចំកិច្ចប្រជុំដើម្បីពន្យល់ពីគោលការណ៍ថ្មីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៤ វេលាម៉ោង៨:៣០នាទីព្រឹក ដោយអញ្ជើញចាប់ពីអនុប្រធាននាយកដ្ឋានឡើងទៅបើអវត្តមានត្រូវសុំច្បាប់ដោយបញ្ជាក់មូលហេតុ។

ជាទីបញ្ចប់ឯកឧត្តមឆ្លៀតក្នុងឱកាសក្នុងទិវាបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរខាងមុខនេះលោកសូមប្រសិទ្ធពរដល់សមាជិកអង្គប្រជុំជួបប្រទះនូវពុទ្ធពរទាំង៤ប្រការគឺអាយុវណ្ណៈសុខៈពលៈកុំបីឃ្លៀងឃ្លាតឡើយនិងទទួលជោគជ័យគ្រប់ភារកិច្ចការងារ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ១១:00ព្រឹក ថ្ងៃ ខែ ឆ្នាំ ដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាល ជាទីបំផុត។

ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤

| បានឃើញ និងឯកភាព | បានឃើញ និងពិនិត្យ | របាយការណ៍រៀបចំដោយ |
|---|---|---|
| អគ្គលេខាធិការ | អនុប្រធាននាយកដ្ឋាន | |
| ឯកឧត្តមវេជ្ជ. តែង គន្ធី | លោកវេជ្ជ. លី ចាន់រ៉ាវុធ | សៀក សុភ័ក្រ្ត |

ទទួល 11-4-14